For an English version, please turn over!

កិច្ចប្រជុំពិគ្រោះយោបល់រវាងរដ្ឋាភិបាលកម្ពុជា និងបណ្តាប្រទេសមួយចំនួន
ភ្នំពេញ ថ្ងៃទី ៦-៧ ខែ ធ្នូ ឆ្នាំ ២០០៤

សេចក្តីថ្លែងការណ៍របស់ប្រទេសស៊ុយអែត

ប្រទេសស៊ុយអែតសូមទទួលស្គាល់ និងស្វាគមន៍ចំពោះការអភិវឌ្ឍន៍ជាវិជ្ជមានជាច្រើន នៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីកិច្ចប្រជុំពិគ្រោះយោបល់ នាពាក់កណ្តាលឆ្នាំ ២០០២ កន្លងទៅ។ មានសុខសន្តិភាពទូទាំងប្រទេស ការបោះឆ្នោត ឆ្នាំ២០០៣ បានប្រព្រឹត្តទៅដោយរៀបរយមួយ ហើយថ្មីត្បិតតែមានការយឺតយ៉ាវក៏ដោយ ក៏ទីបំផុតរដ្ឋាភិបាលមួយត្រូវបានបង្កើតឡើងដោយផ្អែកលើលទ្ធផលនៃការបោះឆ្នោត។ ការជ្រើសតាំងប្រមុខរដ្ឋថ្មីបន្តបានប្រព្រឹត្តទៅយ៉ាងរលូនដោយគ្មានឧបត្ថិហេតុណាមួយកើតឡើងទេ។ សភាជាតិកម្ពុជាបានឱ្យសច្ចានុមតិរួចជាស្រេចលើ សិទ្ធិសញ្ញាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក។ ការរីកចំរើនគួរអោយកត់សំគាល់ក្នុងកិច្ចប្រយុទ្ធប្រឆាំង និងការរីករាលដាលនៃជំងឺ HIV/AIDS។ សមិទ្ធិផលផ្សេងទៀតមានរួមមានភាពប្រសើរឡើងលើអត្រាអក្ខរកម្ម និងអត្រាចុះឈ្មោះចូលរៀន ពិសេសការចុះឈ្មោះចូលរៀនរបស់សិស្សស្រី។ លើសពីនេះទៅទៀត ការបែងចែកនិងការបើកបញ្ជូលាស់ប្រាក់ អោយទៅវិស័យសង្គមកិច្ចក៏បានកើនឡើងផងដែរ។

កិច្ចប្រជុំពិគ្រោះយោបល់នេះ បានផ្តល់ឱកាសឱ្យមានការពិភាក្សាលើចំនុចសំខាន់ៗ និងបញ្ហានានាចំពោះមុខដើម្បីដោះស្រាយនាពេលអនាគតដ៏ខ្ជីខ្ជាងមុខនេះ។ រដ្ឋាភិបាលស៊ុយអែតបានយល់ដឹងពីសារៈសំខាន់នៃការកំណត់ជ្រើសរើសបញ្ហាទាំងអស់នេះ ដែលជាផ្នែកមួយនៃដំណើរការកំណត់ល័ក្ខខ័ណ្ឌព្រមព្រៀងមួយ និងបង្ហាញអំពីគោលបំណងដែលចង់បានជាចាំបាច់សំរាប់ឆ្នាំខាងមុខនេះ។

អភិបាលកិច្ចល្អស្ថិតនៅចំកណ្តាលនៃយុទ្ធសាស្ត្រចតុកោណ ដែលជាវត្ថុបំណងដ៏សំខាន់របស់កម្មវិធីកិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍របស់ប្រទេសស៊ុយអែត ជាមួយប្រទេសកម្ពុជា។ ការឧបត្ថម្ភគាំទ្រពង្រឹងអភិបាលកិច្ចអោយប្រសើរឡើងអាចធ្វើបានតាមរយៈរដ្ឋាភិបាលផង និងតាមរយៈសង្គមស៊ីវិលផង។ ប្រទេសស៊ុយអែត ជឿជាក់ថា មធ្យោបាយទាំងពីរនេះអាចធ្វើបាន។ យើងបានពិចារណាចំពោះការបង្កើតឱ្យមានឡើងនូវច្បាប់ប្រឆាំងនឹងអំពើពុករលួយ ដែលអាចឆ្លើយតបទៅនឹងបទដ្ឋានអន្តរជាតិ ហើយដែលជាសមាសធាតុមួយដ៏ចាំបាច់នៅក្នុងសេចក្តីប្រកាសថ្មីនេះអំពីសង្គ្រាមប្រឆាំងអំពើពុករលួយរបស់រដ្ឋាភិបាលកម្ពុជា។

រដ្ឋាភិបាល និងប្រជាជនស៊ុយអែតមានជំនឿជឿជាក់យ៉ាងខ្លាំងផងដែរថា វាមានសារៈសំខាន់ណាស់មុននឹងឈានទៅដល់ការកាត់ក្តីនៅតុលាការ រឿងក្តីមួយចំនួនស្តីពីអំពើពុករលួយ ត្រូវបានធ្វើការអង្កេតយ៉ាងច្បាស់លាស់ ហើយបំបាត់ចោលនូវវប្បធម៌លើកលែងទោស ដែលបំផ្លាញសង្គមទាំងមូល។ វាមានសារៈសំខាន់ណាស់សំរាប់ចងចាំថា ការខិតខំប្រឹងប្រែងប្រឆាំងនឹងបទឧក្រិដ្ឋកម្មគ្រប់រូបភាពត្រូវតែគោរពទៅតាមកាតព្វកិច្ច សិទ្ធិមនុស្ស និងនីតិរដ្ឋ។

ដំណើរការនៃការកែទំរង់ប្រព័ន្ធច្បាប់ និងតុលាការនាពេលបច្ចុប្បន្ននេះនៅមានកំរិតទាបនៅឡើយ។ នាឆ្នាំខាងមុខច្បាប់ថ្មីៗមួយចំនួនតំរូវអោយមានជាចាំបាច់ ហើយក្នុងដំណើរការរាល់កិច្ចខិតខំប្រឹងប្រែងទាំងនោះត្រូវ តែធានាអោយបាននូវការគោរពសិទ្ធិមនុស្ស។ កិច្ចការពារសិទ្ធិមនុស្សគឺមិនមែនត្រឹមតែ ភាពគ្មានអំពើគំរាមកំហែង ឬក៏ដាក់កំហិតទៅលើសិទ្ធិរបស់ស្ត្រី និងបុរសប៉ុណ្ណោះទេ តែវាជាបញ្ហានៃការការពារមនុស្សជាតិអោយផុតពីការរំលោភ បំពានបំពាន និងការធ្វើអា-ជីវកម្ម ឬការជួញដូរមនុស្ស ហើយជាបញ្ហានៃការផ្តល់សិទ្ធិមនុស្សគ្រប់រូបនូវកំរិតជីវភាពសមរម្យមួយ។

ថ្ងៃត្បិតតែនៅក្នុងប្រទេសក្រីក្រដូចជាប្រទេសកម្ពុជានេះក៏ដោយ ក៏រាល់ជំហ៊ីសដែលអាចធ្វើបានត្រូវតែរកអោយឃើញដើម្បីកិច្ចខិតខំប្រឹងប្រែងសំរេចវត្ថុបំណងនេះ។ កិច្ចការមួយគួរអោយលើកទឹកចិត្តផងដែរក្នុងការប្រយុទ្ធប្រឆាំងនឹង ការជួញដូរមនុស្សគឺអនុសារណៈនៃការយោគយល់ គ្នាមួយត្រូវបានចុះហត្ថលេខានាពេលថ្មីៗនេះ ដោយប្រទេសនៅតាមដងទន្លេមេគង្គទាំងប្រាំមួយ។ កិច្ចព្រមព្រៀងនេះយោងទៅលើគោលការណ៍ណែនាំជាពិសេស សំរាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលចេញផ្សាយដោយគណៈកម្មការជាន់ខ្ពស់សំរាប់សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។

ប្រសិនបើភាពក្រីត្រូវបានកាត់បន្ថយនៅកម្ពុជា នេះមានន័យថា សិទ្ធិរបស់អ្នកក្រត្រូវបានគេការពារផងដែរ។ វិធានការបន្ទាន់នានាត្រូវតែកំណត់ឡើង ដើម្បីធានាថារាល់ការធ្វើសម្បទានទាំងអស ់គឺធ្វើឡើងស្របទៅតាមគោលការណ៍អភិបាលកិច្ចល្អ នីតិរដ្ឋ និងនិរន្តរភាព។ នៅក្នុងទស្សនៈរបស់ប្រទេសស៊ុយអែត ការគោរពសិទ្ធិដ៏ពេញលេញនៃ ការបញ្ចេញយោបល់ ពត៌មាន និងនីតិរដ្ឋ គឺជាមូលដ្ឋានស្នូលសំរាប់ការអភិវឌ្ឍន៍សេកិច្ចប្រកបដោយនិរន្តរភាព។ សង្គមស៊ីវិលគួរតែត្រូវបានអនុញ្ញាតអោយចូលរួមជាសំខាន់ ក្នុងការសំរេចឱ្យបាននូវសង្គមយុត្តិធម៌ និងសំបូររុងរឿងមួយ។

កិច្ចការដ៏មានតំលៃរបស់តំណាងពិសេសនៃអគ្គលេខាអង្គការសហប្រជាជាតិអំពីសិទ្ធិមនុស្ស បានបន្តជួយគាំទ្រដល់ការខិតខំអនុវត្តន៏សិទ្ធិមនុស្សបន្ថែមទៀតនៅប្រទេសកម្ពុជា។ ការិយាល័យគណៈកម្មការ ជាន់ខ្ពស់សំរាប់សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា បានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់ការអនុវត្តន៏សិទ្ធិទាំងអស់នេះ។ការលើកស្ទួយ និងការការពារសិទ្ធិមនុស្សនៅក្នុងកិច្ចប្រតិបត្តិការជាមួយប្រព័ន្ធអង្គការសហប្រជាជាតិ ត្រូវអោយបន្តទៅទៀត។

ប្រទេសស៊ុយអែតសូមស្វាគមន៏ការផ្តល់សច្ចានុមតិបស់សភាជាតិកម្ពុជាលើកិច្ចព្រមព្រៀងជាមួយ និងអង្គការ-សហប្រជាជាតិស្តីអំពីការកាត់ទោសខ្មែរក្រហម ហើយនិងរំពឹងដល់ការអនុវត្តន៏កិច្ចព្រមព្រៀងនេះយ៉ាងពេញលេញ។ ប្រទេសស៊ុយអែតបានឧបត្ថម្ភកិច្ចខិតខំប្រឹងប្រែងនៃការងារវិមជ្ឈការ និងសហវិមជ្ឈការនៅកម្ពុជា តាំងពីយូរមកហើយ ដែលជាមធ្យោបាយមួយដើម្បីលើកស្ទួយអភិបាលកិច្ចមូលដ្ឋាន ហើយនិងការ វិនិយោគដែលបានអនុម័ត និងយល់ព្រមពីថ្នាក ់មូលដ្ឋានដើម្បីកាត់បន្ថយភាពក្រីក្រ។ រដ្ឋាភិបាល ស៊ុយអែតសន្យានឹងបន្តផ្តល់ជំនួយឧបត្ថម្ភនេះតទៅទៀត។ ក៏ប៉ុន្តែ ក្របខ័ណ្ឌនយោបាយមួយសំរាប់បន្តការគាំទ្រដល់ការខិតខំកំណែទំរង់វិមជ្ឈការ និងសហវិមជ្ឈការតំរូវអោយបង្កើតឡើងនៅដើមឆ្នាំ ២០០៥ ខាងមុខនេះ។ ក្របខ័ណ្ឌនេះគួរតែផ្តោតទៅលើមធ្យោបាយនាពេលខាងមុខហើយនិងបង្ហាញថាតើបណ្តាបទពិសោធន៏ ដែលមានកន្លងមកនឹងត្រូវបានយកមកប្រើប្រាស់អោយបានល្អបំផុតសំរាប់អនាគត យ៉ាងដូចម្តេច។ បច្ចុប្បន្ន ដំណើរការនេះ គឺស្ថិតនៅត្រង់ចំនុចប្រសព្វមួយ ដ៏សំខាន់ ហើយដែលតំរូវអោយមានការខិតខំប្រឹងប្រែងទាំងឡាយពីគ្រប់មជ្ឈដ្ឋានដើម្បីបង្កើតកម្មវិធីមួយដែលអាចធ្វើបានដែលនឹងទាក់ទាញជំនួយឧបត្ថម្ភពីបណ្តាប្រទេសម្ចាស់ជំនួយរួមគ្នាបាន។

លើសពីនេះទៅទៀតការងារដែលកំពុងតែដំណើរការគឺដាក់អោយអនុវត្តន៏នូវកម្មវិធីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈពេញលេញប្រកបដោយមហិច្ឆតាថ្មី។ កិច្ចការនេះអាចចាត់ទុកជាឧទាហរណ៍មួយនៃអភិបាលកិច្ចល្អ ក្នុងការអនុវត្តន៏ជាក់ស្តែង ហើយជាមធ្យោបាយសំរាប់បង្កើតប្រព័ន្ធតម្លាភាពមួយនៃការពង្រឹងគណនេយ្យភាពក្នុងការប្រើប្រាស់ថវិការ សាធារណៈ។ ប្រទេសស៊ុយអែតបានចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងទាំងនេះ ហើយ នឹងសន្យាបន្តជួយឧបត្ថម្ភលើកម្មវិធី នេះថែមទៀត។

ចំពោះការអភិវឌ្ឍនីវិស័យកសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិដែលបានកំណត់ជាមាគ៌ាចំបងសំរាប់ខ្ទឿនសេដ្ឋកិច្ចកម្ពុជា គឺនៅមានបញ្ហាជាច្រើនដែលតំរូវអោយដោះស្រាយ។ មានទិដ្ឋភាពពីរដែលត្រូវដោះស្រាយ ជាបន្ទាន់ គឺគួរ

តែពង្រឹងតម្លាភាពនៃការគ្រប់គ្រងធនធានធម្មជាតិរបស់រដ្ឋតាមរយៈការផ្សព្វផ្សាយបន្ទាន់ ជា សាធារណៈនូវកិច្ចសន្យាទាំងឡាយអោយបានល្អ ហើយនិងការគ្រប់គ្រង ព្រៃសម្បទានសំខាន់ផ្សេងៗទៀត ។

ប្រព័ន្ធត្រួតពិនិត្យដ៏ជាក់លាក់មួយគួរតែត្រូវបានបង្កើត ហើយការពិន័យត្រូវតែមាននៅពេលដែលមានការរំលោភលើកិច្ចសន្យា ។ ចំពោះសកម្មភាពដោះមីន ដែលឧបត្ថម្ភដោយប្រទេសស៊ុយអែត អស់រយៈពេលជាច្រើនឆ្នាំមកហើយតំរូវជាបន្ទាន់អោយរដ្ឋាភិបាលទទួលយកនូវភាពជាអ្នកសំរបសំរួលធនធានសមរម្យ និងដំណើរការល្អមួយសំរាប់កិច្ចការនេះក្នុងឆ្នាំបន្ទាប់ ។

បណ្តាលទ្ធផលព្រាងទុកដែលបានសំរេចក្នុងវិស័យអប់រំ ដែលជួយឧបត្ថម្ភដោយប្រទេសស៊ុយអែតក្នុងបរិបទនៃវិធីសាស្ត្រអភិវឌ្ឍន៍ទូទាំងវិស័យ បានលើកឡើងពីខាងដើមរួចហើយ ។ ក៏ប៉ុន្តែកន្លងមកនៅមានការព្រួយបារម្ភមួយ គឺការបើកបញ្ចេញសាច់ប្រាក់ទៅអោយវិស័យនេះ មានភាពយឺតយ៉ាវ និងមិនគ្រប់ចំនួន ។ ដូចគ្នានេះដែរគឺតំរូវអោយមានការគិតគូរដល់ភាពប្រាក់ឈ្នួលរបស់គ្រូបង្រៀន ដែលជាផ្នែកមួយនៃកម្មវិធីកំណែទំរង់ប្រាក់ឈ្នួលរបស់មន្ត្រីរាជការទូទៅ ហើយដោះស្រាយបញ្ហា ផ្សេងៗ ទៀតដែលទាក់ទិនទៅនិងការអនុវត្តន៍ការងារមិនបានល្អក្នុងវិស័យសាធារណៈ ។

នៅក្នុងកិច្ចសហប្រតិបត្តិការជាមួយប្រទេសកម្ពុជា ប្រទេសស៊ុយអែតបានអនុវត្តន៍វិធីសាស្ត្រចំពោះសហប្រតិ-បត្តិការអភិវឌ្ឍន៍ និងការសំរបសំរួល ។ ស្របគ្នានេះមានន័យថាប្រទេសស៊ុយអែតបានបញ្ជូនជំនួយឧបត្ថម្ភភាគច្រើនរបស់ខ្លួនដល់ប្រទេសកម្ពុជា តាមរយៈបណ្តាដៃគូរអភិវឌ្ឍន៍ទ្វេភាគី និងស្ថាប័នហិរញ្ញវត្ថុពហុភាគី ។ វិធីអនុវត្តន៍នេះបានទទួលស្គាល់ដោយរដ្ឋាភិបាលកម្ពុជា ហើយបច្ចុប្បន្នប្រទេសស៊ុយអែតគឺជាដៃគូរអភិវឌ្ឍន៍មួយនៅក្នុង កម្មវិធីវិស័យអប់រំ វិមជ្ឈ-ការ និងសហវិមជ្ឈការ ។ រយៈពេលពីរឆ្នាំកន្លងមកនេះ ប្រទេសកម្ពុជាមានការអភិវឌ្ឍន៍គួរឱ្យកត់សំគាល់នៅក្នុងផ្នែកសំរបសំរួល ការពង្រឹងភាពជាម្ចាស់ និងការលើកទឹកចិត្តអោយបណ្តាប្រទេសម្ចាស់ជំនួយសំរបទៅតាមការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងវិស័យផ្សេងៗ ។ ការបង្កើតក្រុមបច្ចេកទេសការងារត្រូវបានប្រកាសជាផ្លូវការនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ត្រៀមនាខែកញ្ញា ឆ្នាំនេះ ហើយនឹងក្លាយទៅជាឧបករណ៍ដ៏សំខាន់មួយក្នុងបរិបទនាពេលបច្ចុប្បន្ននេះ ។ ប្រទេសស៊ុយអែតបានជួយគាំទ្រយ៉ាងពេញទំហឹងចំពោះការខិតខំរបស់រដ្ឋាភិបាល ហើយនឹងបន្តជាដៃគូរសន្យាមួយនៅក្នុងដំណើរការនេះដែលមានបំណងពង្រឹងកិច្ចសហប្រតិបត្តិការ និងការសំរបសំរួលប្រកបដោយប្រសិទ្ធិភាព ។

ជារួម ជំនួយអភិវឌ្ឍន៍របស់ស៊ុយអែតដល់ប្រទេសកម្ពុជាក្នុងឆ្នាំ ២០០៣ មានចំនួន ១៤៣ លាន ក្រូន័រ ដែលសមាមាត្រនឹងប្រហែលជា ២០ លានដុល្លារសហរដ្ឋអាមេរិក រួមទាំងជំនួយតាមរយៈអង្គការក្រៅរដ្ឋាភិបាលផ្សេងៗទៀត ។ ជំនួយអភិវឌ្ឍន៍ក្នុងឆ្នាំ ២០០៤ នេះ រំពឹងថាស្ថិតនៅក្នុងកំរិតជំនួយដដែល ។ ចំណែកឯឆ្នាំ ២០០៥ តំរោងផែនការផ្តល់ ជំនួយឧបត្ថម្ភរបស់ប្រទេសស៊ុយអែត នឹងស្ថិតនៅក្នុងកំរិតដូចគ្នាទៅនឹងបណ្តាឆ្នាំកន្លងមក ថ្វីត្បិតតែកិច្ចព្រមព្រៀងសហប្រតិ-បត្តិការអភិវឌ្ឍន៍ នឹងឈានទៅដល់ទីបញ្ចប់ចំពោះ ត្រីវិស័យ ដែលជួយឧបត្ថម្ភដោយប្រទេសស៊ុយអែត ។ តំរោងការបន្តជួយដល់វិស័យអប់រំ ការអភិវឌ្ឍន៍ជនបទ វិមជ្ឈការ និង អន្តរាគមន៍លើអភិបាលកិច្ចនានានឹងបន្តទៅទៀត ។ ការផ្តល់ជំនួយសរុបសំរាប់ឆ្នាំ ២០០៥ គឺសង្ឃឹមថាមានចំនួន ២០ លានដុល្លារ សហរដ្ឋអាមេរិក ដែលរួមបញ្ចូលទាំងជំនួយចំនួន ៣ លានដុល្លារសហរដ្ឋអាមេរិក ដល់អង្គការក្រៅរដ្ឋាភិបាលសំរាប់អន្តរាគមន៍លើសិទ្ធិមនុស្ស និងការបណ្តុះបណ្តាល ។